ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ១៣...០១៩...៦០៤.ប្រកាសព័ត៌មាន

*ថ្ងៃចន្ទ ១៣រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*
*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៩*

# សេចក្ដីបំភ្លឺ
## ស្ដីពី "ទុនបម្រុងអន្តរជាតិ"

ធនាគារជាតិនៃកម្ពុជាសង្កេតឃើញថា សារព័ត៌មានមួយចំនួនបានបកស្រាយខុសពាក់ព័ន្ធនឹងទុនបម្រុងអន្តរជាតិ។ ការប្រៀបធៀបរវាងទំហំទុនបម្រុងអន្តរជាតិនឹងចំនួនខែនៃការនាំចូលទំនិញនិងសេវាគឺមានលក្ខណៈបច្ចេកទេស ដើម្បីវាស់វែងពីភាពរឹងមាំនៃសេដ្ឋកិច្ច និងមិនពាក់ព័ន្ធជាមួយនឹងបញ្ហានយោបាយឡើយ។

យោងតាមមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ទុនបម្រុងអន្តរជាតិនៃប្រទេសមួយ សំដៅលើទ្រព្យសម្បត្តិដែលទទួលស្គាល់ជាអន្តរជាតិ ដែលប្រទេសមួយមាន និងត្រូវបានគ្រប់គ្រងដោយអាជ្ញាធររូបិយវត្ថុ សម្រាប់ប្រើក្នុងករណីចាំបាច់ដូចជា ការផ្ដល់ហិរញ្ញប្បទានដល់ជញ្ជីងទូទាត់ប្រសិនបើមានតម្រូវការ, ការធ្វើអន្តរាគមន៍លើទីផ្សារប្ដូរប្រាក់ដើម្បីគ្រប់គ្រងការប្រែប្រួលអត្រាប្ដូរប្រាក់ និងការរក្សាជំនឿទុកចិត្តលើរូបិយវត្ថុនិងសេដ្ឋកិច្ចជាតិ។ ទុនបម្រុងអន្តរជាតិអាចមានទម្រង់ជាមាសនិងរូបិយប័ណ្ណនានាដែល IMF ទទួលស្គាល់ជាអន្តរជាតិ (ដូចជា ប្រាក់ដុល្លារអាមេរិក អឺរ៉ូ ផោនអង់គ្លេស យេនជប៉ុន និងយ៉ន់ចិន)។

IMF តែងតែផ្ដល់អនុសាសន៍ឱ្យប្រទេសសមាជិក រក្សាកម្រិតទុនបម្រុងអន្តរជាតិឱ្យបានគ្រប់គ្រាន់។ ដើម្បីកំណត់កម្រិតគ្រប់គ្រាន់នេះ IMF តែងតែធ្វើការប្រៀបធៀបទំហំទុនបម្រុងអន្តរជាតិទៅនឹងចំនួនខែនៃការនាំចូលទំនិញនិងសេវានៅគ្រាខាងមុខ។ ចំពោះប្រទេសកំពុងអភិវឌ្ឍន៍ដូចកម្ពុជា កម្រិតគ្រប់គ្រាន់អប្បបរមានៃទុនបម្រុងអន្តរជាតិដែលគួរមានគឺចំនួន ៣ ខែនៃការនាំចូលទំនិញនិងសេវានៅគ្រាខាងមុខ។

ចំពោះកម្ពុជា ទុនបម្រុងអន្តរជាតិបានកើនឡើងជាលំដាប់ ហើយបច្ចុប្បន្នមានកម្រិត ៥ ខែនៃការនាំចូលទំនិញនិងសេវា ពោលគឺខ្ពស់ជាង ៣ ខែ ដែលជាកម្រិតអប្បបរមាដែលប្រទេសកំពុងអភិវឌ្ឍន៍គួរមាន។ ផ្អែកលើសូចនាករនេះ សេដ្ឋកិច្ចកម្ពុជាកំពុងអភិវឌ្ឍប្រកបដោយចីរភាពនិងភាពរឹងមាំ។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

សូមទំនាក់ទំនង៖
ធនាគារជាតិនៃកម្ពុជា
នាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ចនិងសហប្រតិបត្តិការអន្តរជាតិ
ទូរសព្ទ៖ ០២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh